FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ

ឆ្នាំទី ៥ លេខ ៥៥ ខែធ្នូ ឆ្នាំ២០០៦

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute



# ពូជស្រូវកណ្តាល "ខា ៣"

ពូជស្រូវ "ខា៣" ជាពូជស្រូវកណ្តាល ដែលបានធ្វើការបញ្ចេញ និងផ្សព្វផ្សាយជូនកសិករប្រើប្រាស់ដោយ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាឆ្នាំ ១៩៩៥។ បច្ចុប្បន្ន ពូជខា៣ បាននឹងកំពុងពេញនិយមក្នុងចំណោមប្រជាកសិករ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយពូជស្រូវនេះផ្តល់នូវទិន្នផលខ្ពស់ គុណភាពអង្ករល្អប្រសើរ។

## លក្ខណៈពិសេសៗរបស់ពូជស្រូវខា ៣

ពូជស្រូវខា៣ ជាពូជស្រូវប្រកាន់រដូវ ចាប់ចេញផ្កាក្នុងកំឡុងថ្ងៃទី ៣០ ខែតុលា ទៅដល់ថ្ងៃទី ០៧ ខែវិច្ឆិកា អាស្រ័យទៅលើអាកាសធាតុ និងពេលវេលាដាំដុះ។ កម្ពស់ដើមរបស់ពូជស្រូវខា៣ ប្រែប្រួលពី ១២០-១៧០ ស.ម និងចំនួនដើមបែកផ្តល់ផលគឺចាប់ពី ៧-១០ ដើមក្នុងមួយគុម្ព អាស្រ័យទៅតាមប្រភេទដី។ ចំនួនគ្រាប់ក្នុងមួយក្ងួរមានចាប់ពី ១១០-១៥០ គ្រាប់ និងមានប្រវែងក្ងួរ ២០-២៥ ស.ម។ ពូជស្រូវខា៣ មិនធន់ទៅនឹងមមាចត្នោតទេ តែធន់ទ្រាំមធ្យមទៅនឹងភាពរាំងស្ងួត និងមានទិន្នផលពី ២,៥ ទៅ ៤,៥ តោនក្នុង ១ ហិកតា។

## វិធីសាស្ត្រដាំដុះ

**សម្រាប់**ស្រូវសន្ទូង បរិមាណគ្រាប់ពូជដែលចាំបាច់គឺពី ៣០-៤០ គីឡូក្រាម ក្នុងមួយហិកតា ប៉ុន្តែក្នុងករណីដែលគ្រាប់ពូជសុទ្ធ និងមានសុខភាពល្អ ព្រមទាំងគ្រប់គ្រងទឹកបាន និងថែទាំបានល្អ បរិមាណគ្រាប់ពូជដែលត្រូវការក្នុងមួយហិកតា គឺពី ១៥-២០ គីឡូក្រាមប៉ុណ្ណោះ។ ដើម្បីឲ្យសំណាបដុះលូតលាស់ធំធាត់ល្អ គេត្រូវសាបគ្រាប់ពូជ មួយគីឡូក្រាមលើផ្ទៃដីថ្នាល ១០ ម៉ែត្រការ៉េ។ ទីសំណាបត្រូវធ្វើនៅជិតប្រភពទឹក តែត្រូវឆ្ងាយពីម្លប់ព្រៃ ឬកន្លែងមានភ្លើងអគ្គីសនី ដើម្បីចៀសវាងការបំផ្លាញពីសត្វល្អិតចង្រៃ។ ជាការល្អ គួរស្ទូងសំណាបដែលមានអាយុ ២៥-៣០ ថ្ងៃ ហើយក្នុងមួយគុម្ពចំនួន ២-៣ ដើម។

សម្រាប់ស្រូវពង្រោះ បរិមាណគ្រាប់ពូជដែលចាំបាច់គឺពី ៦០ គីឡូក្រាមក្នុងមួយហិកតា។ គួររៀបចំដីឲ្យបានល្អ និងរាបស្មើមុនស្ទូង ឬព្រោះ។ ការភ្ជួររាស់ គួរតែធ្វើឲ្យបាន ២-៣ សារ ជាការល្អប្រសើរ។ ប្រសិនបើស្រែអាចបញ្ចេញបញ្ចូលទឹកបានបន្ទាប់ពីស្ទូង ឬព្រោះបាន ២០ ថ្ងៃអាចបញ្ចេញទឹកឲ្យអស់ពីក្នុងស្រែ ២-៤ ថ្ងៃ រួចបញ្ចូលទឹកថ្មីវិញ។ ធ្វើរបៀបនេះ គឺដើម្បីធ្វើឲ្យស្រូវកាន់តែបែកគុម្ពល្អ។





## ការប្រើប្រាស់ជី

ការប្រើប្រាស់ជីសមស្របតាមកម្រិតណែនាំ នឹងមិនបណ្តាលឲ្យមានការថយចុះ ឬបាត់បង់ក្លិន ឬគុណភាពដទៃទៀតឡើយ។ គួរដាក់ជី ២-៣ ដង ក្នុងមួយវដ្តជីវិតរបស់ស្រូវ។ បាចទ្រាប់បាតមុនពេលស្ទូង ដោយប្រើជីធម្មជាតិពី ៥ តោន (២០ រទេះ) ក្នុង ១ ហិកតា និងរួមផ្សំជាមួយជីគីមីដូចមានក្នុងតារាងទី ១។ បរិមាណជីបាចបំប៉នលើកទីមួយ និងលើកទីពីរ ត្រូវអនុលោមតាមតារាងទី ១ ហើយពេលវេលានៃការបាច ត្រូវអនុលោមតាមតារាងទី ២។



តារាងទី ១

| ប្រភេទដី | បាចទ្រាប់បាត | | | បំប៉ន | |
|---|---|---|---|---|---|
| | ប្រភេទជី | | | លើកទី ១ | លើកទី ២ |
| | អ៊ុយរ៉េ | ដេ អា ប៉េ | ប៉ូតាស្យូម | អ៊ុយរ៉េ | អ៊ុយរ៉េ |
| ដីព្រៃខ្មែរ | ៦-៨ | ១៧-២៥ | ០-៦៧ | ១៧-២៤ | ១៣-១៨ |
| ដីប្រទះឡាង | ២-១៣ | ៥០ | ០-៥០ | ២៩-៤៣ | ២២-៣៣ |
| ដីបាកាន ឬ អូរូង | ២៤ | ៣៨ | ០-៣៤ | ៥២ | ៣៩ |
| ដីទួលសំរោង | ២០-៣៥ | ៥០ | ០ | ៥៣-៨៥ | ៤០-៦៤ |
| ដីក្រគរ | ៥៩ | ៥០ | ០ | ១០៤ | ៧៨ |
| ដីគោកត្រប់ | ១២ | ៥០-៦៧ | ០-៥០ | ៤៣-៥០ | ៣២-៣៨ |
| ដីក្បាលពោធិ៍ | ៥២ | ០ | ០ | ៧០ | ៥២ |
| ដីកំពង់សៀម | ៣៣ | ០ | ០ | ៤៣ | ៣៣ |

តារាងទី ២

| ពេលវេលាសាប | បំប៉នលើកទី ១ | បំប៉នលើកទី ២ |
|---|---|---|
| ១-៣១ មិថុនា | ៣០ ថ្ងៃក្រោយស្ទូង | ៨-១២ កញ្ញា |
| ១-១៥ កក្កដា | ៣០ ថ្ងៃក្រោយស្ទូង | ១៣-១៧ កញ្ញា |
| ១៦-៣០ កក្កដា | ៣០ ថ្ងៃក្រោយស្ទូង | ១៨-២២ កញ្ញា |

## ការប្រមូលផល

- ត្រូវធ្វើការច្រូតកាត់នៅរវាង ៣០-៣៥ ថ្ងៃ បន្ទាប់ពីស្រូវហាលផ្កាស្រុះ ឬពេលដែលប្រមាណ ៨៥ ភាគរយ នៃគ្រាប់ស្រូវទុំ។
- ត្រូវហាល ២-៣ ថ្ងៃ ដើម្បីបន្ថយសំណើមនៅក្នុងគ្រាប់ឲ្យនៅ ១៤ ភាគរយ មុននឹងទុកជាការល្អ។ សូមយកគ្រាប់ស្រូវមកខាំដើម្បីកំណត់ បើគ្រាប់ស្រូវនោះបាក់ គឺមានន័យថាគ្រាប់ស្រូវស្ងួតល្អអាចទុកដាក់បាន។
- គ្រាប់ពូជត្រូវច្រកទុកនៅក្នុងថង់ប្លាស្ទិកចងឲ្យជិត រួចដាក់ក្នុងបាវមួយជាន់ទៀត ហើយទុកដាច់ដោយឡែកពីគ្រាប់ស្រូវចំណីនៅកន្លែងដែលស្ងួតល្អ និងគ្មានការបំផ្លាញពីសត្វកណ្តុរ មាន់ ទាជាដើម។ ត្រូវសរសេរឈ្មោះពូជ និងថ្ងៃខែច្រូតកាត់ ដាក់នៅលើបាវឲ្យបានត្រឹមត្រូវល្អ។
- ផលស្រូវដែលប្រមូលបាន ត្រូវទុកដាក់ក្នុងជង្រុកឲ្យបានល្អដោយការពារកុំឲ្យសត្វកណ្តុរ មាន់ ទា ចូលស៊ី និងមិនឲ្យទទឹក។






សម្រាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យរុក្ខជម្រើសវិទ្យា មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ ភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ ០១ ភ្នំពេញ

ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ គេហទំព័រ: www.cardi.org.kh

ទូរអក្សរ: pbreed@cardi.org.kh trin@cardi.org.kh hunyadana@cardi.org.kh